# I- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៨៧ អនក្រ.បក
### ស្តីពីការបង្វែរឥណទាន

***

**រាជរដ្ឋាភិបាល**

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស-៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នរ/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានចំណាយទៅតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

បានឃើញលិខិតលេខ ៥០៩ សឧ.ថហ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០ របស់ក្រសួងសុខាភិបាល

យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១ .- ត្រូវបានអនុញ្ញាតអោយបង្វែរឥណទានថវិកាចំនួន ៦.៣៧០.៤៦២.៤២៥ រៀល (ប្រាំមួយពាន់បីរយចិតសិបលានបួនរយហុកសិបពីរពាន់បួនរយម្ភៃប្រាំរៀលគត់) ពីជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈនិងការផ្គត់ផ្គង់តូច) ទៅជំពូក១៣ (សកម្មភាព នៃកម្មវិធី) របស់មន្ទីរសុខាភិបាល ខេត្ត ក្រុង នៃក្រសួងសុខាភិបាល សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដូចខាងក្រោម ៖

ឯកតាគិតរៀល

| ល.រ | ខេត្ត-ក្រុង | ជំពូក | ឥណទានដើមឆ្នាំ | ការប្រែប្រួលឥណទាន | | ស្ថានភាព ឥណទានថ្មី |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| ១ | កំពង់ចាម | 11 | 3.700.000.000 | | 2.419.089.155 | 1.280.910.845 |
| | | 13 | | 2.419.089.155 | - | 2.419.089.155 |
| ២ | សៀមរាប | 11 | 1.660.000.000 | | 1.357.652.900 | 302.347.100 |
| | | 13 | | 1.357.652.900 | - | 1.357.652.900 |
| ៣ | កំពង់ធំ | 11 | 1,287.000.000 | - | 1.011.487.300 | 275.512.700 |
| | | 13 | | 1.011.487.300 | | 1.011.487.300 |
| ៤ | ពោធិសាត់ | 11 | 638.000.000 | - | 375.481.200 | 262.518.800 |
| | | | | | | 375.481.200 |
| | | 13 | | 375.481.200 | | |
| ៥ | កំពង់ឆ្នាំង | 11 | 1.030.000.000 | | 550.348.100 | 479.651.900 |
| | | 13 | | 550.348.100 | - | 550.348.100 |
| ៦ | ក្រុងព្រះសីហនុ | 11 | 450.000.000 | - | 373.742.670 | 76.257.330 |
| | | 13 | | 373:742.670 | - | 373.742.670 |
| ៧ | ស្ទឹងត្រែង | 11 | 427.000.000 | - | 282.661.100 | 144.338.900 |
| | | | | 282.661.100 | - | 282.661.100 |
| | សរុប | 11 | 9.192.000.000 | - | 6.370.462.425 | 282.1537.575 |
| | | 13 | | 6.370.462.425 | - | 6.370.462.425 |

មាត្រា ២ ._ ឥណទានថវិកាក្នុងមាត្រា ១ ខាងលើ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ របស់មន្ទីរសុខាភិបាលខេត្តកំពង់ចាម ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តពោធិសាត់ ខេត្តកំពង់ឆ្នាំង ក្រុងព្រះសីហនុ និងខេត្តស្ទឹងត្រែង នៃក្រសួងសុខាភិបាល សំរាប់ចំណាយលើការងារកម្មវិធីសកម្មភាពជាអាទិភាពសំរាប់ឆមាសទី២ ឆ្នាំ ២០០០ ។

មាត្រា ៣ ._ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្ត

អនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

***

**អនុក្រឹត្យលេខ ៨៨ អនក្រ.បក**

**ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

***

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ